# កិច្ចព្រមព្រៀងធ្វើវិនិយោគ

## កិច្ចព្រមព្រៀងនេះ ធ្វើនៅថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ ១៩៩៨

## រវាង

## រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (ដែលគេសន្មត់ថាជារដ្ឋាភិបាល ) ជាភាគីទី១

## និង

ក្រុមហ៊ុនសាជីវកម្ម **PHEA PIMEX Co., Ltd** ជាក្រុមហ៊ុនមួយដែលមានសាជីវកម្មនៅប្រទេសកម្ពុជា ត្រូវបានចុះបញ្ជី ដែលមានការិយាល័យរបស់ខ្លួន ផ្ទះលេខ ១៧ ផ្លូវ ៥៥ សង្កាត់ចាក់អង្រែ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ (855).919436 ទូរសារ (855.23).723133 (ក្នុងនេះគេសន្មត់ថាជាអ្នកធ្វើវិនិយោគ ព្រមទាំងអ្នកមានសិទ្ធិទទួលបន្ត ពីខ្លួននិងការចាត់តាំងរបស់ខ្លួន )ជាភាគីទី២ ។

ដោយហេតុថា : រដ្ឋាភិបាលបានអញ្ជើញអ្នកវិនិយោគអោយមកធ្វើវិនិយោគ និង ជួយអភិវឌ្ឍន៍ឧស្សាហកម្មឫស្សី និងក្រដាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ដោយហេតុថា : រដ្ឋាភិបាលមានបំណងផ្តល់អោយអ្នកវិនិយោគនូវព្រៃឫស្សីសម្បទានចំនួនប្រមាណ ៣០០ ០០០ ហិកតា នៅក្នុងខេត្តបាត់ដំបងនិងបន្ទាយមានជ័យ ក្នុងនោះផ្ទៃដីដែលមិនបានចាត់ជាព្រៃនិងឫស្សីត្រូវបានដកចេញ ( ក្នុងនេះគេសន្មត់ថាជាតំបន់សម្បទាន ) ហើយអ្នក វិនិយោគមានបំណងទទួលយកតំបន់សម្បទាននេះពីរដ្ឋាភិបាល សំរាប់ផលិតកម្មធំបងគីក្រដាស និង ផលិតផលដែលទាក់ទិនទៅនឹងឫស្សីនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមល័ក្ខខ័ណ្ឌផ្សេងៗដូចមានចែងស្រាប់នៅក្នុងកិច្ចព្រមព្រៀងនេះ ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោមនេះ :

### ប្រការទី ១: ការធ្វើគំរោងវិនិយោគ និង ការផ្តល់តំបន់សម្បទាន

យោងតាមការយល់ព្រមបណ្តាក់ទុនរបស់អ្នកវិនិយោគក្នុងរយះពេល៣ឆ្នាំ ដែលមានទឹកប្រាក់ចំនួន ១២ ០០០ ០០០ ដុល្លា អាមេរិក សំរាប់ហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចដំណើរការផលិតកម្មក្រដាសជាតំណាក់កាលៗ (ក្នុងនេះគេសន្មត់ថាជាគំរោង ) នៅក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលនិងផ្តល់តំបន់សម្បទានអោយទៅអ្នកវិនិយោគជាមួយ និង សិទ្ធផ្តាច់មុខដើម្បីកាប់ដកហូតឫស្សីសំរាប់កែច្នៃ ដើម្បីបន្ថែមតំលៃក្នុងគំរោងដែលពោលខាងលើ និងធ្វើកិច្ចសន្យាផ្សេងៗដែលសំរាប់ត្រូវបានគេចាត់ទុកថាសមស្រប និង ការចាំបាច់ដើម្បីសំរេចតាមគោលដៅ ទាំងឡាយដែលបានរៀបរាប់ខាងលើ ។

### ប្រការទី ២ : ការគ្រប់គ្រងទិន្នផលដែលអាចធានាស្ថេរភាពបាន

អ្នកវិនិយោគត្រូវដំណើការអាជីវកម្មតំបន់សម្បទាននេះស្ថិតក្រោមការគ្រប់គ្រងទិន្នផល ដែលអាចធានាបាន ក្នុងរយះពេល ៥ ឆ្នាំ សំរាប់ខួបអាជីវកម្មឫស្សី ។

## ប្រការទី ៣ : សម្បទានដីទៃទៀត

៣.១ ផ្ទៃដីផ្នែកខ្លះនៃតំបន់សម្បទាននេះ ដែលជាកម្មសិទ្ធិស្របច្បាប់របស់ប្រជាជនក្រុមហ៊ុនគ្មានសិទ្ធិប្រើប្រាស់ផ្ទៃដីនោះ សំរាប់ប្រតិបត្តិការនោះទេលុះត្រាតែមានការទទួលអនុញ្ញាតិពីប្រជាជនរស់នៅក្នុងតំបន់នោះជាមុន សិន ។

៣.២ ផ្ទៃដីផ្នែកខ្លះនៃតំបន់សម្បទានដែលត្រូវ បានកំនត់ដោយអាជ្ញាធរមាន សមត្ថកិច្ច និង ម្ចាស់ព្រៃឫស្សីសម្បទានថាមិន សមស្របចំពោះប្រតិបត្តិការព្រៃឫស្សីសម្បទាននឹងត្រូវកាត់ចេញសំរាប់គំរោងអភិវឌ្ឍន៍ដោយរាជរដ្ឋាភិបាល ។

## ប្រការទី ៤ : រយៈពេលនៃតំបន់សម្បទាន និង ការអនុញ្ញាតិបន្ត

៤.១ ដំណាក់កាលដំបូងសំរាប់តំបន់សម្បទានដែល បានផ្តល់អោយនោះគឺ ២៥ឆ្នាំ ហើយរយៈពេលនេះអាចត្រូវសុំអនុញ្ញាតិបន្ត ធ្វើឡើងវិញសារជាថ្មីរយៈពេល ២៥ ឆ្នាំថែមទៀត ដោយរក្សាទុកនូវលក្ខខ័ណ្ឌដដែល ។

៤.២ ការអនុញ្ញាតិបន្តនូវតំបន់សម្បទានទាំងមូល ឬមួយផ្នែកនៃតំបន់ដល់សាខាបុត្រសម្ព័ន្ធឬសម្ព័ន្ធក្រុមហ៊ុនដែលជាក្នុងក្របខ័ណ្ឌកេស៊ីរួមគ្នានោះ រឺដល់ភាគីទី៣ ចាំបាច់ត្រូវមានការយល់ព្រមពីរាជរដ្ឋាភិបាលជាមុន ។

## ប្រការទី ៥ : ការស្ថាបនាអាគារ

អ្នកវិនិយោគនឹងមានសិទ្ធិស្ថាបនា អភិវឌ្ឍន៍ ដំណើរការ ធ្វើអោយប្រសើរឡើង និង ថែទាំរក្សារោងចក្រក្រៀសអេហាដ្ឋាន យានដ្ឋាន រោងជាង អាគារផ្សេងៗ កំពង់ផែផ្សេងៗ និង រចនាសម្ព័ន្ធព្រមទាំងទីកន្លែងផ្សេងទៀតដើម្បីអភិវឌ្ឍន៍គំរោងទាំងឡាយក្នុងតំបន់សម្បទានរឺទីតាំងដីទៃទៀតដែលកំណត់ដោយអ្នកវិនិយោគ សមស្របទៅនឹងច្បាប់គ្រប់គ្រងព្រៃឈើ ។

## ប្រការទី ៦ : ទីតាំងនៃអាគារ

អ្នកវិនិយោគនឹងមានសិទ្ធិប្រើប្រាស់ឬជួលដីដោយចេញតំលៃឈ្នួលដោយខ្លួនឯង ក្នុងករណីចាំបាច់ដើម្បីប្រើប្រាស់សំរាប់ ទីតាំងរោងចក្រផ្សេងដែលមានទំនាក់ទំនងទៅនឹងគំរោងទាំងមូលដែលខ្លួនបានគ្រោងទុក ។ រាជរដ្ឋាភិបាលនឹងផ្តល់ដល់អ្នកវិនិយោគនូវការជួយគាំទ្រ និង សហប្រតិបត្តិការអោយបានសមស្រប ។

## ប្រការទី ៧ : អំពីពន្ធដារ

៧- ១ មាត្រាទី៧នេះគឺជាកម្មវត្ថុស្ថិតក្រោមច្បាប់ស្តីពីវិនិយោគទុននៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើកាលពីខែ សីហា ឆ្នាំ ១៩៩៤ និង អនុក្រឹត្យពាក់ព័ន្ធ ។

៧- ២ អនុលោមតាមច្បាប់ស្តីពីវិនិយោគនិងលើកទឹកចិត្តដូចដែលបានបញ្ជាក់ក្នុងមាត្រា ១៤ ដែលមានចែងក្នុងច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

៧- ៣ អ្នកវិនិយោគអាចធ្វើការតវ៉ាទៅរាជរដ្ឋាភិបាលក្នុងកំឡុងពេល១២០ថ្ងៃ ក្រោយពេលបញ្ចប់នៃថវិកាឆ្នាំ ។ ការរៀបរៀងនៃគណនីពិស្តារអនុលោមទៅតាមបទដ្ឋានគណនីអន្តរជាតិ និង ត្រូវធ្វើការជំរះបញ្ជីដោយស្ថាប័នជំរះបញ្ជីឯករាជ្យខាងក្រៅដែលបានធ្វើការងារតាមបទដ្ឋានដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ។

## ប្រការទី ៨ : ការបង់ថ្លៃសួយសារ

៨- ១ ការបង់ថ្លៃសួយសារត្រូវអនុវត្តទៅលើឫស្សីសំរាប់កែច្នៃប៉ុណ្ណោះ ។ ប្រាក់នេះត្រូវបង់ជារៀងរាល់ខែក្នុងកំឡុង ៣០ថ្ងៃ បន្ទាប់ពីដាច់ខែនីមួយៗ ។ គំរោងអាត្រាថ្លៃនៃការបង់ សួយសារត្រូវអនុវត្តចំពោះឫស្សីដែលជំពិតដោយ

អ្នកវិនិយោគដោយគោរពទៅតាមគំរោងការងារទាំងមូល ដូចមានចែងក្នុងកិច្ចព្រមព្រៀងដោយមានប្រសិទ្ធិភាពចាប់ពីកាលបរិច្ឆេទនៃផលិតផលឫស្សី ។ អត្រានៃថ្លៃសួយសារឫស្សី នឹងត្រូវផ្អែកលើគោលការណ៍គិតថ្លៃឫស្សីដែលត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។

៨ - ២ រាជរដ្ឋាភិបាលរក្សាសិទ្ធគ្រប់ពេលក្នុងការផ្លាស់ប្តូរ ( ប្រែប្រួល ) ពាក់ព័ន្ធអត្រា Royalty ដែលមិនត្រូវអនុវត្តន៍លើឫស្សីដែលផលិតដោយវិនិយោគិន ។ រាល់ការផ្លាស់ប្តូរនៃអត្រាពន្ធ Royalty និងត្រូវផ្តល់ជា លាយល័ក្ខអក្សរ អោយវិនិយោគិនមិនអោយហួសពីរយៈពេល ២ ខែ នៃកាលបរិច្ឆេទបង់ថ្លៃសួយសារ Royalty ថ្មីនឹងត្រូវអនុវត្តន៍ ។

## ប្រការទី ៩ : ការគិតថ្លៃផលិតផល

អ្នកវិនិយោគ ត្រូវបានទទួលការអនុញ្ញាតិអោយធ្វើការចរចានូវលក្ខណះបច្ចេកទេសរបស់ផលិតផល វិទំហំ និងកំណត់ថ្លៃផលិតផលរបស់ខ្លួនដើម្បីនាំចេញដោយគ្មានការកំហិតអ្វីទាំងអស់ ។

## ប្រការទី ១០ : ការប្រើប្រាស់កំលាំងពលកម្មក្នុងស្រុកនិង បរទេស

១០-១ អ្នកវិនិយោគត្រូវប្រើពលកម្មជនជាតិខ្មែរ ។ រាជរដ្ឋាភិបាលនិងមិនអនុញ្ញាតិអោយអ្នកវិនិយោគប្រើប្រាស់ជនជាតិផ្សេងទៀតក្រៅពីជនជាតិខ្មែរ ដោយអនុលោមទៅតាមច្បាប់ពលកម្ម ច្បាប់ស្តីពីវិនិយោគចុន ច្បាប់អន្តោប្រវេសន៍ ច្បាប់ពាក់ព័ន្ធដទៃទៀត ។ រាជរដ្ឋាភិបាលអនុញ្ញាតិអោយប្រើប្រាស់ជនបរទេសមិនមែនជាជនជាតិខ្មែរក្នុងករណីចាំបាច់នៅពេល ដែល រកពុំបាន គ្រប់គ្រាន់នូវកម្មករជំនាញជាជនជាតិខ្មែរ ។

១០- ២ រាជរដ្ឋាភិបាលធានាផ្តល់លិខិត និង ការអនុញ្ញាតិអោយធ្វើការងារ ទិដ្ឋាការនិងឯកសារចាំបាច់ផ្សេងៗទៀតអោយដល់ និយោជិត ឬ កម្មករបរទេសរបស់អ្នកវិនិយោគដោយគិតគួររួមទាំងសហព័ន្ធផង ដើម្បីអោយចូលមកធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

១០- ៣ អ្នកវិនិយោគត្រូវរៀបចំអោយបានច្បាស់លាស់ ព្រមទាំងអនុវត្តនូវកម្មវិធីបណ្តុះបណ្តាលដល់កម្មករក្នុងស្រុកសំដៅ បង្កើនមុខជំនាញរបស់ពួកគេ ដោយផ្សារភ្ជាប់ទៅនឹងគំរោងការងារផ្សេងៗ ក៏ដូចជាការបង្កើនសមត្ថភាពទទួលខុសត្រូវខ្ពស់របស់ ពួកគេ ។

## ប្រការទី ១១ : ការបញ្ចប់កិច្ចការ

១១- ១ អ្នកវិនិយោគមានសិទ្ធិដកខ្លួនចេញពីគំរោងការងារទាំងមូល ឬ គំរោងការងារណាមួយបានគ្រប់ពេលវេលា ប្រសិនបើអ្នកវិនិយោគត្រូវបានទទួលការអនុញ្ញាតិអោយបញ្ជូននិយោជិក និងកម្មករបរទេសរបស់ខ្លួនព្រមទាំងសហព័ន្ធ តេវិលត្រឡប់ទៅមាតុភូមិរបស់ខ្លួនវិញជាបន្តបន្ទាប់ និង ប្រកបដោយសុវត្ថិភាព ហើយការដកត្រឡប់ទៅវិញ ឬ ការលក់សំភារៈបរិក្ខា រោងចក្រ នាវា ដាក់ម៉ាស៊ីន នាវាផ្ទុកទំនិញ យានយន្តផ្សេងៗ និងប្រដាប់ប្រដាព្រមទាំងទ្រព្យសម្បត្តិកម្មសិទ្ធិផ្សេងៗទៀតដោយមិនមានការបង់ប្រាក់ពិន័យ និងពន្ធណាមួយឡើយដោយអនុលោមទៅតាមច្បាប់អន្តរជាតិ (បេដ្ឋារបនាសម្ព័ន្ធ ) និងបទបញ្ញត្តិ ផ្សេងៗ ។

១១-២ ក្នុងករណីអ្នកវិនិយោគ សុំដកខ្លួនថយដោយខ្លួនឯងនោះ អ្នកវិនិយោគត្រូវទទួលខុសត្រូវតាមមាត្រាទី ២៣ នៃច្បាប់ វិនិយោគ ។

១១- ៣ ប្រសិនបើអ្នកវិនិយោគមិនបានអនុវត្តពេញលេញ នូវបណ្តាលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀង ឬ សេចក្តីសំរេចនានា

នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាមានសិទ្ធបញ្ឈប់កិច្ចព្រមព្រៀងនេះដោយគ្មានលក្ខខ័ណ្ឌ និងការសងប្រាក់បង់ខាត។ ការមិនអនុវត្តនេះនឹងផ្តល់ជាលទ្ធផលដល់អ្នកវិនិយោគនូវការបង់ខាតប្រាក់កក់ជូនដល់រាជរដ្ឋាភិបាល ដោយ អនុលោមទៅតាមមាត្រាទី ១៣ នៃអាជ្ញាប័ណ្ណសំរាប់ធ្វើអាជីវកម្មព្រៃឫស្សី ។

១១- ៤ ក្នុងករណីដែលអ្នកវិនិយោគពុំមិនបានគោរពតាមសេចក្តីសំរេចនៃកិច្ចព្រមព្រៀងនេះ និងមិនបានចាប់ផ្តើមសកម្មភាពពោលគឺដូកម្មក្នុងតំបន់សម្បទានក្នុងកំឡុងពេល ១ឆ្នាំចាប់ពីការបរិច្ឆេទនៃកិច្ចព្រមព្រៀងនេះ រាជរដ្ឋាភិបាលកម្ពុជា មានសិទ្ធបញ្ឈប់កិច្ចព្រមព្រៀងដោយគ្មានលក្ខខ័ណ្ឌ និង ដោយគ្មានការសងការបង់ខាត ។ ការបញ្ឈប់នេះនឹងផ្តល់ដល់អ្នកវិនិយោគនូវការបង់ខាតប្រាក់កក់ជូនរាជរដ្ឋាភិបាលដោយអនុលោមតាមមាត្រាទី ១៣ នៃអាជ្ញាប័ណ្ណសំរាប់ធ្វើអាជីវកម្មព្រៃឫស្សី ។

## ប្រការទី ១២ : ហេដ្ឋារចនាសម្ព័ន្ធ

១២- ១ អ្នកវិនិយោគត្រូវប្រើប្រាស់នូវ ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកប្រើប្រាស់ដីទៃទៀតដែរ ទីណាដែលមានការខ្វះខាត ឬ ទីណាដែលត្រូវការកែលំអរបន្ថែមទៀតនោះ អ្នកវិនិយោគត្រូវតែទទួលគេផ្តល់អោយនូវលិខិតអនុញ្ញាតិផ្សេងៗ តាមរយៈការស្នើសុំទៅរដ្ឋាភិបាល ឬ អាជ្ញាធរពាក់ព័ន្ធនានា ដើម្បីស្តារនិងពង្រីកទីកន្លែងដែលមានស្រាប់ ឬ ស្ថាបនាទីកន្លែងផ្សេងទៀត តាមលក្ខខ័ណ្ឌផ្សេងៗ ដែលបានព្រមព្រៀងគ្នា ។ រដ្ឋាភិបាលនឹងមិនដកហូត ឬ ពន្យាកិច្ចព្រមព្រៀងរបស់ខ្លួនដោយមិនសមហេតុផលឡើយ ។

១២-២ អ្នកវិនិយោគអាចបង្កើតគំរោងសំណង់ផ្សេងៗ ដែលខ្លួនយល់ថាចាំបាច់សំរាប់ :

ក - ដំណើរផែនការ ការងារផ្សេងៗទៀតដែលស្ថិតនៅក្នុងតំបន់សម្បទាន ដោយគិតរួមទាំងការស្ថាបនាផ្លូវ សំរាប់ សំរាប់ដំណើរការអាជីវកម្មព្រៃឫស្សី ក៏ដូចជាការស្ថាបនាព្រែកជីក កន្លែងស្តុកទុកទឹកព្រលាង សំរាប់ស្តុកឫស្សី ការរៀបចំជំរុំគុបកោងជួសជុល ការស្ថាបនាការិយាល័យនិងគេហដ្ឋាននានា សំរាប់និយោជិកទាំងឡាយ ក៏ដូចជាការផ្តល់នូវកន្លែងផ្សេងៗ ដែលទាក់ទងទៅនឹងសង្គមកិច្ចដូចជា សាលារៀន មន្ទីរព្យាបាលរោគ និងវត្តអារាមផ្សេងៗ ។

ខ - សំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ផ្សារភ្ជាប់ជាមួយដំណើរការឧស្សាហកម្មព្រៃឫស្សី ដូចជាការស្ថាបនារោងការ ឧស្សាហកម្ម ការប្រើប្រាស់ទឹក ភ្លើងព្រមទាំងការស្ថាបនាអាគាររដ្ឋាភិបាល ឬ គេហដ្ឋាន ទីលំនៅ សំរាប់បុគ្គលិក និង កំលាំងពលកម្ម ។

គ - ការដំណើរការងារ ដែលស្ថិតនៅក្រៅរង្វង់ដីសម្បទាន ត្រូវមានការឯកភាពពីអាជ្ញាធរត្រឹមត្រូវ ។

ឃ- ការបញ្ឈប់នៃកិច្ចព្រមព្រៀងនេះក្នុងមូលហេតុណាមួយ ប្រសិនបើអ្នកវិនិយោគគ្រោងឡើងវិញ ក៏យកចេញនូវមធ្យោបាយសំភារៈណាមួយក្នុងតំបន់សម្បទាន ធ្វើអោយខូចដល់បរិស្ថាន ដោយការស្ថាបនា ការផ្លាស់ប្តូរ ការដក យកចេញ ការកែប្រែ ហេដ្ឋារចនាសម្ព័ន្ធ ត្រូវតែធ្វើការកែតំរូវ ។

១២- ៣ ផ្លូវថ្នល់និង ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដទៃទៀត ដែលសាងសង់ដោយអ្នកវិនិយោគ ក្នុងតំបន់សម្បទាននេះ ត្រូវបានត្រួតពិនិត្យយ៉ាងពេញលេញការប្រើប្រាស់ដោយអ្នកវិនិយោគ ។ ផ្លូវទាំងនេះអាចប្រើប្រាស់ដោយរាជរដ្ឋាភិបាល យោធា និងប្រជាជនកម្ពុជា ។ ច្បាប់ចរាចរផ្លូវថ្នល់ ដោយឡែកដែលបានរៀបចំក្រោយពិភាក្សារវាងអ្នកវិនិយោគ និងប្រធានសាធារណការ និង ដឹកជញ្ជូន សំរាប់ធ្វើអាជីវកម្មក្នុងតំបន់សម្បទាន និង អាចអនុវត្តបាន ។

## ប្រការទី ១៣ : ការការពារសិទ្ធិ

រាជរដ្ឋាភិបាលធានាអោយអ្នកវិនិយោគទទួលសិទ្ធិផ្សេងៗ និង តំបន់សម្បទានដែលបានផ្តល់អោយនៅក្នុងកិច្ចព្រមព្រៀងនេះ ក៏ដូចជាកិច្ចព្រមព្រៀងបន្តបន្ទាប់ដែលបានធ្វើឡើងដោយភាគីទាំងពីរ ក្នុងគោលបំណងធ្វើអោយភាគីនិមួយៗគោរព និង អនុវត្តតាមប្រការចាំបាច់ផ្សេងៗ ដើម្បីធានាសកម្មភាពបណ្តាភាគីទី ៣ ដូចជាការមិនកំណត់អ្នកកាប់ឬស្សីដែលនឹងមិនរាំងរាំងដល់កិច្ចការ និង សកម្មភាពរបស់អ្នកវិនិយោគ និង គំរោងការងារផ្សេងៗនៅ ក្នុងកិច្ចព្រមព្រៀងនេះ ឬ កិច្ចព្រមព្រៀងបន្តបន្ទាប់ ហើយប្រសិនបើផ្នែកខ្លះនៃតំបន់សម្បទានបានត្រូវគេអនុវត្តដើម្បីវត្ថុបំណងសាធារណៈផ្សេងៗ ដូចជាឧទ្យាននានា តំបន់ដីទំនេរទៀត មិនត្រូវបានរាជរដ្ឋាភិបាលផ្តល់អោយជំនួសវិញទេ ។ រាជរដ្ឋាភិបាលនឹងផ្តល់ ឬ សហការព្រមទាំងជួយឧបត្ថម្ភក្នុងការយល់ព្រមធានា និង ផ្តល់លិខិតអនុញ្ញាតិផ្សេៗ និងបង្កលក្ខណៈងាយស្រួលចំពោះការ អនុម័តយល់ព្រមពីរបៀបរបបទាក់ទងនឹង រដ្ឋាភិបាល ច្បាប់តុលាការនិតិប្រតិបត្តិ ឬ បែបបទរដ្ឋបាល ។ ដូច្នេះការមិនកំណត់របៀបរបបដែលធ្លាប់មានពីមុនមកនោះ ប្រសិនបើមានការព្រឹត្តិល្មើសបណ្តាលមកពីភាគីទី ៣ ណាមួយនោះ អ្នកវិនិយោគក៏មិនមានសិទ្ធិដោះស្រាយជាមួយភាគី ទី៣ ទៅតាមលទ្ធភាព ដែលអាចធ្វើទៅបាន ។

## ប្រការទី ១៤ : អប្រតិកម្ម

រាជរដ្ឋាភិបាលបញ្ជាក់ធានាអះអាងថា ប្រសិនបើជាមានការកែប្រែណាមួយចំពោះ ច្បាប់ ក្រឹត្យច្បាប់ ឬ បទបញ្ញត្តិនានានាំអោយប៉ះពាល់ដល់ការកែប្រែសិទ្ធិ ឬ កាតព្វកិច្ចផ្សេងៗរបស់អ្នកវិនិយោគក្នុងកិច្ចព្រមព្រៀងនេះ ឬ កិច្ចព្រមព្រៀងដទៃទៀត រវាងភាគីទាំងពីរ ឬ រាំង ឬ បន្ថយការធ្វើរូបិយប័ណ្ណ ឬការប្រកាសពីប្រាក់ចំណេញ ឬ បន្ថយនូវដំណើរការ ឬប្រាក់ចំណូលរបស់អ្នកវិនិយោគ ដែលកើតឡើងពីគំរោងការផ្សេងៗដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះ ឬ កិច្ចព្រមព្រៀងដទៃទៀតរវាងភាគីទាំងពីរនោះ រាជរដ្ឋាភិបាលនឹងចាត់វិធានការចាំបាច់ និង សមស្របដើម្បីស្តារ ឬដោះស្រាយពីសិទ្ធិ និង កាតព្វកិច្ចរបស់អ្នកវិនិយោគ ។

## ប្រការ ទី១៥ : កម្មសិទ្ធិ និង ការចាត់ចែងគ្រប់គ្រង

អ្នកវិនិយោគត្រូវធ្វើសំណើសុំសេចក្តីសំរេច ឬអនុញ្ញាតិបន្តពីរាជរដ្ឋាភិបាលនូវផ្នែកមួយ ឬទាំងមូលនៃកិច្ចព្រមព្រៀងនិងតំបន់សម្បទាន ក៏ដូចជាកិច្ចព្រមព្រៀងផ្សេងៗទៀត ហើយសិទ្ធិនិងកាតព្វកិច្ចនេះមានចំពោះសាខាមួយ ឬច្រើនផ្នែកសាខាផ្សេងៗ ក្រុមហ៊ុនចំណុះ រឺក្រុមហ៊ុនសម្ព័នណាមួយដែលធ្វើជាមួយ អ្នកវិនិយោគនោះ ។ ការប្រកាសនៃសំណើណាមួយដើម្បីសុំសេចក្តីសំរេចពីភាគីណាមួយដែលបានពោលខាងដើមត្រូវតែធ្វើយ៉ាងតិច ៦ខែ មុនពេលកាលបរិច្ឆេទនៃការសំរេចមូលជាធរមាន និងប្រសិនបើបាន អនុមតិភាគីដែលពាក់ព័ន្ធ និងមានសិទ្ធិ និង កាតព្វកិច្ចក្នុងការសំរេច ។

## ប្រការទី ១៦ : ប្រធានសក្តិ

ប្រសិនបើការខកខាន ឬការពន្យាក្នុងពេលបំពេញការងារ ឬ កាតព្វកិច្ចរបស់ភាគីណាមួយដែលកើតឡើងអំពីព្រឹត្តិការណ៍ដែលហួសពីការគ្រប់គ្រងរបស់ពួកគេនេះ ការខកខានបែបនេះមិនត្រូវចាត់ទុកថាជាការប្រព្រឹត្តល្មើសនឹងកិច្ចព្រមព្រៀងនោះឡើយ ។ ព្រឹត្តិការណ៍បែបនេះ រួមមានករណីប្រធានសក្តិ ( ដោយគ្មានការកំណត់ ) ការធ្វើកូដកម្ម ការរំជើបរំជួល សង្គ្រាម ភាពជ្រួលច្របល់ ការប៉ះបោរ ភាពអមិត្តផ្សេងៗ និងសកម្មភាពផ្សេងៗណាមួយរបស់រដ្ឋាភិបាល ដែលនឹងរារាំងការពារអនុវត្តន៍នៃកាតព្វកិច្ចរបស់ភាគីណាមួយ ។

## ប្រការទី ១៧: ការធានារាប់រង

រាជរដ្ឋាភិបាលនឹងគាំទ្រចំពោះពាក្យសុំណាមួយរបស់អ្នកវិនិយោគ ឬ ក៏ពាក្យសុំរបស់អ្នកដែលត្រូវគេជ្រើសរើសអោយឈរឈ្មោះ ព្រមទាំងបញ្ជូនដោយរួសរាន់នូវឯកសារចាំបាច់ ដែលគាំទ្រដល់ពាក្យសុំរបស់អ្នកវិនិយោគ ដើម្បីអោយបានទទួលនូវការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ខាងផ្នែកនយោបាយ និងពាណិជ្ជកម្ម ដោយរួមទាំងការអត់កំណត់ MIJA OPIC ឬអ្នកធានារ៉ាប់រង ភ្នាក់ងារដ៏ទៃទៀតដែលជ្រើសរើសដោយអ្នកវិនិយោគ ។

## ប្រការទី ១៨ : ការប្រកាសផ្សេងៗ

ការប្រកាសណាមួយនឹងត្រូវចាត់ទុកថាបានប្រគល់អោយ លុះត្រាតែសរសេរជាលាយលក្ខណ៍អក្សរដោយប្រគល់អោយ ផ្ទាល់ ឬ តាមប៉ុស្តិ៍ប្រៃសណីយ៍អនុសិទ្ធ ឬ តាម (facsimile) ដោយបញ្ជាក់ពីការទទួលផង ។

## ប្រការទី ១៩: ការយល់ព្រម

នៅពេលណាមានការស្នើសុំការយល់ព្រមក្រោមកិច្ចព្រមព្រៀងនេះ ការយល់ព្រមបែបនេះនឹងមិនត្រូវបានគេបដិសេធ ឬ ពន្យារពេលដោយមិនសមហេតុផលឡើយ ។

## ប្រការទី ២០: ការកែពែ្ញក

នៅពេលដែលមានការយល់ព្រមនៅក្នុងប្រការណាមួយនៃកិច្ចព្រមព្រៀងនេះ ត្រូវបានពិនិត្យឃើញថាមិនត្រឹមត្រូវតាមលក្ខណៈច្បាប់មានភាពមិនសមស្របឬមិនអាចអនុវត្តបានក្នុងប្រការណាមួយនោះ សុពលភាព ភាពស្របច្បាប់និងភាពដែលអាច អនុវត្តបាននៃប្រការទាំងឡាយដែលនៅសេសសល់ព្រមទាំងពាក្យសុំណាមួយ នឹងមិនត្រូវប៉ះពាល់ឡើយ ។

## ប្រការទី ២១: និយមន័យ និងការបកស្រាយ

២១-១ ក្នុងកិច្ចព្រមព្រៀងនេះពាក្យផ្សេងៗនិងមានន័យដូចខាងក្រោមនេះ :

ក / - Export មានន័យផ្លាស់ប្តូរ ឬប្រែប្រួលទៅតាមវេយ្យាករណ៍ហើយពាក្យសំដែងចេញក្នុងនេះមានន័យថា "នាំចេញពីព្រះរាជាណាចក្រកម្ពុជា " ។

ខ / - Or " ឬ " Other " ផ្សេងទៀត " និង Otherwise " ម្យ៉ាងទៀត " មានការខុសគ្នាហើយមិនមានន័យប្រហាក់ប្រហែលគ្នាទេលុះត្រាតែដាក់បន្ថែមពាក្យ " Similar " ឬពាក្យមានន័យប្រហាក់ប្រហែលគ្នាថែមទៀត ។

គ / - ព្រៃឫស្សី រួមមានដើមឫស្សីទាំងឡាយ ឬផ្នែកនៃដើមឫស្សីណាមួយ ទោះបីជាមិនទាន់កាប់ឬរំលំហើយមានន័យថាជាឫស្សីទាំងឡាយដែលដុះនៅក្នុងប្រទេសកម្ពុជា ។

ឃ / - " Products " រួមមានក្រដាសជាផលិតផលសំរេចដែលបានមកពីការកែច្នៃឫស្សី ។

ង / - អាជ្ញាប័ណ្ណសំរាប់ធ្វើអាជីវកម្មឫស្សី គឺជាឯកសារភ្ជាប់ទៅនិងកិច្ចព្រមព្រៀង និងអោយនិយមន័យ ទៅលើលក្ខខ័ណ្ឌ និង ពាក្យដែលប្រើដោយអ្នកវិនិយោគ ក្នុងការអនុវត្តក្នុងតំបន់សម្បទាន ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២១- ២ ក្នុងកិច្ចព្រមព្រៀងនេះ " ពាក្យ" "Word " ស្ថិតក្នុងឯកវចនៈ និងគិតរួមទាំងពហុវចនៈផងហើយ " Words" នៅ ក្នុងពហុវចនៈ និងរួមបញ្ចូលទាំងឯកវចនៈផង ។

## ប្រការទី ២២: កិច្ចព្រមព្រៀងទាំងមូល

ចំពោះកិច្ចព្រមព្រៀងដែលបានលើកឡើងនេះជា កិច្ចព្រមព្រៀងទាំងមូលរវាងរដ្ឋាភិបាលនិងអ្នកវិនិយោគ ដោយមានកំណត់កាលបរិច្ឆេទនៅដើមដំបូងជាលាយលក្ខណ៍អក្សរ ហើយទាក់ទិនទៅនិងកម្មវត្ថុដែលចែងក្នុងកិច្ចព្រមព្រៀងនេះនិង

បដិសេធចោលនូវការពិភាក្សា និងការយល់ដឹងពីអ្វីៗដែលមានពីមុនមក ដែលមិនមានចែងក្នុងកិច្ចព្រមព្រៀងនេះរវាងរាជរដ្ឋាភិបាល និងអ្នកវិនិយោគ ។ គ្មានការកែប្រែឬបដិសេធកិច្ចព្រមព្រៀងនេះឬពុំមានប្រការណាមួយដែលមិនត្រូវធ្វើការជាកំហិតទៅលើភាគីណាមួយឡើយ លុះត្រាតែមានការសរសេរជាលាយលក្ខណ៍អក្សរ ហើយត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរ ។

## ប្រការទី ២៣ : ភាសា

កិច្ចព្រមព្រៀងនេះធ្វើឡើងជាពីរភាសាគឺភាសាខ្មែរ និង អង់គ្លេសហើយក្នុងពេលដែលមានជំលោះ គេនឹងយកអត្ថបទជាភាសាអង់គ្លេសធ្វើជាមូលដ្ឋានក្នុងការជជែកគ្នា ។ ដើម្បីជាសាក្សីភាគីទាំងពីរត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះចាប់តាំងពីកាលបរិច្ឆេទដែលបានកំណត់ជាលាយលក្ខណ៍អក្សរនៅដើមដំបូងនៃកិច្ចព្រមព្រៀងនេះ ។

ចុះហត្ថលេខាដោយ រាជរដ្ឋាភិបាលតាមរយៈតំណាងរបស់ខ្លួន
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ចាន់-សារុន

ចុះហត្ថលេខាដោយ
PHEA PIMEX Co., Ltd
តាមរយៈ តំណាងរបស់ខ្លួន

ឧកញ៉ា. ឡាវ_ម៉េងឃីន

# ផែនទីចង្អុលបង្ហាញទីតាំងស្នើសុំដីសម្បទាន

របស់ក្រុមហ៊ុន PHEAPIMEX CO., LTD ចំនួន 310,000 Ha

ស្ថិតនៅភូមិសាស្ត្រ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ ៦៧២ សជណ.

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ១៩៩៨

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សូមជំរាបមក**

ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**កម្មវត្ថុ** : ករណីសុំផ្តល់ដីសម្បទានព្រៃឫស្សី ជូនក្រុមហ៊ុនភាពីម៉ិច នៅខេត្តបន្ទាយមានជ័យ ចំនួន ៧០.០០០ ហិកតា (ចិតសិបពាន់ហិកតា) និងខេត្តបាត់ដំបងចំនួន ២៣០.០០០ហិកតា (ពីររយសាមសិបពាន់ហិកតា) សរុប ៣០០.០០០ហិកតា (បីរយពាន់ហិកតា) ដើម្បីបង្កើតរោងចក្រផលិតក្រដាសសំរាប់នាំចេញ ។

**យោង** :-លិខិតលេខ ២០០២ កសក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៩៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-លិខិតលេខ ៣៤២ សជណ.កស ចុះថ្ងៃទី ១៨-០៤-១៩៩៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-លិខិតលេខ ២៥៩ សជណ.កស ចុះថ្ងៃទី ១៧-០៣-១៩៩៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-ចំណារឯកឧត្តមនាយករដ្ឋមន្ត្រីទី១ ចុះថ្ងៃទី ០៥-០៦-១៩៩៨

-ចំណារសម្តេចនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី ២៥-០៥-១៩៩៨

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជំរាបឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបថា : រាជរដ្ឋាភិបាលបានសំរេចផ្តល់ដីសម្បទានព្រៃឫស្សីនៅខេត្តបន្ទាយមានជ័យ ចំនួន ៧០.០០០ហិកតា និងនៅខេត្តបាត់ដំបងចំនួន ២៣០.០០០ហិកតា សរុបមានចំនួន ៣០០.០០០ហិកតា ជូនក្រុមហ៊ុនភាពីម៉ិចតាំងអស់ ដើម្បីធ្វើវិនិយោគបង្កើតរោងចក្រផលិតក្រដាសសំរាប់នាំចេញ ដោយក្រុមហ៊ុន SIPING FIFA WOOD INDUSTRY Co. LTD មិនបានអនុវត្តតាមលក្ខខណ្ឌ តាមសំណើហើយ ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះ អំពីយើងខ្ញុំ ។/

**ចម្លងជូន** :

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ក្រសួងមហាផ្ទៃ

-ក្រសួងការពារជាតិ

-សាលាខេត្តបន្ទាយមានជ័យ

-សាលាខេត្តបាត់ដំបង

-ខុទ្ទកាល័យឯកឧត្តមនាយករដ្ឋមន្ត្រីទី១

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២

-ឯកសារ

**ជ.សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ស៊ុំ ម៉ានិត**  **នួន អានួន**

**ព្រះរាជាណាចក្រ កម្ពុជា**

**Kingdom of Cambodia**

**រាជរដ្ឋាភិបាល កម្ពុជា**

Royal Government of Cambodia

**ជាតិ សាសនា ព្រះមហាក្សត្រ**

Nation Religion King

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ១៩៩៨

## <u>លិខិតប្រទានសិទ្ធិពេញលេញ</u>

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-យោងព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

-យោងព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងព្រះរាជក្រឹត្យលេខ នស.រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-យោងព្រះរាជក្រឹត្យលេខ នស.រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងព្រះរាជក្រឹត្យលេខ ជស.រកត-១០៩៧-១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

### រាជរដ្ឋាភិបាលកម្ពុជា

ប្រទានសិទ្ធិជូនឯកឧត្តម តាវ សេងហួរ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទនូវសិទ្ធិពេញលេញ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយក្រុមហ៊ុនភាពីម៉ិច លើអាជ្ញាប័ណ្ណសំរាប់ធ្វើអាជីវកម្មព្រៃឫស្សីសម្បទាន ប្រមាណ ៣០០.០០០ ហិកតា ស្ថិតនៅខេត្តបាត់ដំបងនិងខេត្តបន្ទាយមានជ័យ ដើម្បីបង្កើតរោងចក្រផលិតក្រដាស ។

នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២នៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានសិទ្ធិពេញលេញហើយមានការទុកចិត្តឯកឧត្តម តាវ សេងហួរ បានចុះហត្ថលេខាលើលិខិតប្រទានសិទ្ធិនេះជាភស្តុតាង ។

**អ៊ឹង ហួត**

នាយករដ្ឋមន្ត្រីទី១

**ហ៊ុន សែន**

នាយករដ្ឋមន្ត្រីទី២

# Investment Agreement
## This agreement had made on dated, 12th June 1998

## Between
## Royal Government of Cambodia (hereinafter referred to as party A)
## And

Pheapimex Co.., Ltd which have office address # 17 Road No. 55 Sangkat Chaktomok, Khan Donpenh, Phnom Penh Municipal, Tel: (855) 919 436 Fax (855 23) 723 133 (hereinafter referred to as party B).

**By the result that**: Government had invited the investor to make the business and help to develop bamboo industry and paper production in Cambodia.

**By the result that**: the Royal Government of Cambodia had willing to provided 300,000 hectares of bamboo concession land located in Battambang and Bantey Mean Chey provinces to the investor (Pheapimex Company), and in the concession land that has no bamboo will take out (And this they conclusion as concession) and the investor had willing to accept these bamboo concession land for product paper factory and other production that have related with bamboo according to others Cambodia's stipulations which had written in agreement.

**Both parties had to agree as following:**

**Article 1: Investment plan and provided concession area.**

Reference to of investment to make business in three years, company have capital money amount **12,000,000 US$** for infrastructure and for run paper production factory as step by step (conclusion as a plan) and government will provide the full rights to the company to operate felled bamboo for product the paper and other thing as mention above.

**Article 2: Management on output could be guarantee.**

The company had to run business on this bamboo concession land area under output management, which guarantee in five years for bamboo investment.

**Article 3: Others Concessions**

3.1 Some part of bamboo concession's land area which is belong to local people the company has no rights to use on that land, unless have agreed from the them first.

3.2 Some parts of bamboo concession land, which had limited by power authorities, but the company owner said that it is useful to be as bamboo concession and these will kept for government development area.

**Article 4: Duration of bamboo concession area and making more contracts.**

4.1 Bamboo concession land has duration in 25 years for the first step, and this period could be continue more by kept the same conditions.

4.2 If the company need to transfer bamboo concession lands area or some part of concession land to any sub-constructor or other companies or third party had to have agreement from the government first.

**Article 5: Building Construction.**

The investor will have rights to construct such as house, garage workshop, other buildings, ports and others system and other development places, others plans and other locations that limited by the company owner according to forest management's law.

**Article 6: The building's Location.**

The investor has rights to use bamboo concession land area or rent other lands by themselves in the case for build factory that had designed by the company. And the government will supported and good cooperated to investor.

**Article 7: Taxes**

7.1 Article seven is under Royal Government of Cambodia t investment's law and other concern sub-degrees which Brakas on, August 1994.

7.2 According to investment's law and encouragement's law, which had confirmed in article 14 of Royal Government of Cambodia investment's law.

7.3 The investor could be complaint to government in duration 120 days after finished yearly fund. Accountancy is doing as international standard and clearance account list by the independent clearance list that monitoring team international standard.

**Article 8: Royalty Payment.**

8.1 Royalty payment need to practice on processing bamboo only, the company had to pay in monthly duration of 30 days by the end of the month. The royalty's plan practice on bamboo produced only, and the investor had to respect on work plan, which had written in agreement, and had came in force since dated. The Royal Government of Cambodia is party to limited royalty rate.

8.2 The Royal Government of Cambodia had kept rights to changing (irregular) of royalty rate to investor. Every changing royalty rates will inform to investor not more than two month by written letters of new royalty payment.

**Article 9: Limited the cost of production**

The investor was allowed to discuss on technical of production or size and making the price of their own production for exported without limited.

**Article 10: Local workers and internal workers.**

10.1 Investor had to use Khmer workers only; Royal Government of Cambodai did not allow company to using foreign workers according to labour law, investment law, immigrations law and other concern laws. And Royal Government of Cambodia could allow foreign workers in case could not find enough of Khmer technical workers.

10.2 The government guarantee to provided any document letters and visa and others necessaries documentation to the overseas investor and internal workers and including of federal for working in Royal Government of Cambodia.

10.3 The investor had to make clear management and had to train to local workers of their job by accompany of others plans as to create their responsibilities.

**Article 11: The end of work.**

11.1 The investor has rights to back away from work-plan if the investors need to sent back of their employee and foreign workers or other federal to their homeland , the equipment such as factory, ship, barge, machineries and other properties the investor could sole out without pay fine or taxes according to law (infrastructure) or other dispositions.

11.2 The investor nee to back away by himself or herself so they had to respect on article No23 of investment's law.

11.3 If the investor did not practice on the condition of agreement or other decision of Royal government of Cambodia's law, the government has rights to cancel this contract without make condition or pay compensation. This case will cause the investor lost their deposit money, according to article 13 of permit letter of bamboo industry law.

11.4 Investor did not respect on the decisions this agreement and did not start business in duration one year since the dated of agreement, Royal government of Cambodia has rights to cancellation agreement without making any condition and will not pay compensation. Investor will loss their deposit money according to article 13 of permit letter to make bamboo production.

**Article 12: Infrastructure**

12.1 The investor had to use old infrastructure somewhere are missing and some place need to recorrect more, the investor was provided other permit letters by requesting to the government or other concern authorities to rehabilitated and enlarge the old places or situation of other places according to others conditions that had agreed with each other. The government will not take back or delay the agreement without any result.

12.2 The investor could construct building as they understanding it is necessaries as followings.

A. As other work plan, which is inside bamboo concession land areas including build the road for bamboo production work, digging small stream, pound for storage the bamboos, garages for repair, office and others houses for the workers, and provided some place more such as the school, hospitals and pagoda.

B. Other construction of infrastructure for running paper industry such as constructs factory, water supply, electricity, government building and other house for the workers and staff.

C. Work system in bamboo concession land area had to agreed from concern authorities.

D. Cancellation on any agreement, when duration the investor broke down any thing inside bamboo concession land area and it causes to damage the environment by construction, changing of infrastructure so the investor need to correct.

12.3 Roads and other infrastructure transportations, which built by the investor inside the bamboo concession land area had to inspect by the investors. And Royal Government of Cambodia, militaries and local people have rights to use this road. And traffic law will make after discussed between investor with the Ministry of public and transportation.

**Article 13: The protecting rights**

The government had to guarantee to investors and concession area that prided to investors or other agreement which made by both parties, in purpose to make each party to respect on and practice on in case necessaries activities of third party, such as no limited members of bamboo cutters, that it is couldn't obstruct of works and the investor's activities and other work plan in this agreement or other agreements.

The Royal Government will not provide any concession land the company if bamboos forest area were taking for using public such as national park or other things. But the government will provide the cooperating and supporting of agreement and provide other permit letters,

agreed help run the documents for contact with government and the court or administrative laws. If the third parties commit the crime, the investor could be result the problem with him/her as possible.

**Article 14: Imprecations**

The Royal Government of Cambodia has to guarantee, if there is any changing of law, law degree or other dispositions cause to changing the rights or other of investor obligations in this agreement or other agreement between both parties or obstruct or cut down capital or Prakas of income or cut down the work happen from other plan the agreement or other agreement of both parties, the government will measuring in necessary and suitable to rehabilitation or resolute with investor.

**Article 15: Ownership and Management**

The investor had to make the proposal of the decision or agreement from the government on any part or hold part of agreement and concession area as the same other agreements and there only one branch·or other companies which is shearing the work together. This Prakas on any proposal of agreement that mention above had to make at least six month before the dated of decision come in force.

**Article 16: Uncertainty**

If there is missing or delay in period of complete the job or any party's obligation that happened event over their management, and this missing is no accept as committed the crime and agreement. This event including uncertainty (no limited) striking, ware, enemies, and other activities of government and will protected and practice of any party's obligation.

**Article 17 Guarantees**

The government will supported on any proposal of the investors or the proposal which chosen to be the leader and sent all the concern documents that supported on investor's proposal will guarantee of political dangerous and business with limited of MIJA OPIC or other guarantors that choose by the investors.

**Article 18 Other Prakas**

Any Prakas had to give directly or post by the letter with confirmed about receiving dated.

**Article 19: Agreement**

When this any proposal of agreement will not disagree or delay without any good result.

**Article 20: describing**

When there is agreement in any article of this agreement, and it is not correct as the law procedure, could not practicing in that article will not accept.

**Article 21: definition on and explaining**

21.1 In this agreement, there are some words have the meaning as fellow:

A/. EXPORT it means change or irregular, according to the grammar this word of this time mean (exporting the goods out from Cambodia).

B/. The words OR, TOTHER and OTHERWISE are difference it has not the same meaning unless they use the word (similar).

C/. Bamboos forest, it means all bamboo trees or one bamboo tree, is already felled or not yet felled which grows in Cambodia.

D/. "Products" it means production from the bamboo.

E/. Permit letter for bamboo product is documenting attached agreement and definition to stipulate and the words, which use by the investor on concession area in Cambodia.

21.2 This agreement the "words" in dictionary including plural words and singular words.

**Article 22: A hold of agreement.**

This agreement had written between the government and investor by limited the dated first by letters and related to subject that had written in this agreement. There is no changing on this agreement or any article to force on any party, unless had written by letters and sign by both parties.

**Article 23: Languages**

This agreement has written in both languages Khmer and English, and if there is conflicts they will take English language to be principal for discussing. For the truly both parties had to practice as follow on this agreement after signed on the dated, the written by the letter.

Representative of government
Minister of MAFF.
Signed and Sealed

**Tao Seng Hour**

The director of Pheapimex Company

Signed and Sealed

**Lao Meng Khin**

**Kingdom of Cambodia**
**Nation Religion King**

**The council Ministries**
**No. 672 Sor Chor Nor**

**Phnom Penh dated, 08th June 1998**

**Cooperated Ministers of council Ministries**
**Address to**
**High- Excellency of MAFF Ministry**

Subject: The case of providing the bamboos concession land to Pheapimex company located in Ban Tey Mean Chey province on amount of land 70,000 hectares (Seventy thousands hectares) and Battambang province on amount of land 230,000 hectares (two hundreds and thirty thousands hectares) for producing the paper for exported out.

Reference: - The letters No. 2001 Kor Sor Kor dated, 08 May 1998 of MAFF.
- The letter No. 342 Sor Chor Nor. Kor Sor dated, 18 April 1997 of Council Ministers.
- The letter No. 342 Sor Chor Nor. Kor Sor dated, 18 April 1997 of Council Ministers.
- The signature of first prime Minister dated, 06th June 1998.
- The signature of second prime Minister dated, 05th June 1998.

According to the mention in the subject and reference of council Minister would like to inform the Minster of MAFF that: The government had provided bamboo concession land located in Ban Tay Mean Chey province on amount of land 70,000 hectares (Seventy thousands hectares) and Battambang province on amount of land 230,000 hectares (two hundreds and thirty thousands hectares) to Pheapimex Company for product the paper for exporting by SIPING RIFA WOOD INDSTRY Co, LTD.

We would like High-Excellency my real wish.

On behalf of cooperated Minister of council Minister.
Secretary of State
Signed and Sealed

Som Maneth and Nov Kanorn

Copy to:
- CDC
- Economic and financial Ministry
- Interior Ministry
- Defence Ministry
- Ban Tay Mean Chey provincial office
- Battambang Provincial office
- Cabinet of first Prime Minister
- Cabinet of Second Prime Minister
- Documentation

**Kingdom of Cambodia**
**Nation Religion King**

**Royal Government of Cambodia**

**Phnom Penh dated, Unclear**

**Authorized letter**

- Has seen the constitution law of Nation Religion King Royal Government of Cambodia.
- Reference to Royal degree dated, 24th September 1993 on appointed the Royal Government of Cambodia.
- Reference to Royal degree dated, 01 November 1993 on appointed members of Royal Government of Cambodia.
- Reference to Royal degree No. Nor Sor. Ror Kor Tor –1094-90 dated, 31 October 1994, on appointed members of Royal Government of Cambodia.
- Has seen the law of management of Council Minister that Prakas by Royal degree on dated, 20th July 1994.
- Reference to Royal Degree No Chor Ror Kor Tor-1097-147 dated 07th August 1997 on appointed members of Royal Government of Cambodia.

**The Royal Government of Cambodia**

Has provided the full rights to Mr. Tav Seng Hour Minister of MAFF to sign on this agreement between the government and the Company (Pheapimex) on the bamboo concession land amount 300,000 hectares located in Battambang and Ban Tay Mean Chey provinces to product the paper factory.

First and second Prime Ministers of Cambodia had believed on the Minister of MAFF Mr. Tav Seng Hour, and had signed on this letter.

Signed and Sealed
First Prime Minister and Second Prime Minister

Ing Hourt and Hun Sen